ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

រវាង

## មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

## ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

និង

## អង្គការ សម្ព័ន្ធសុខភាពកុមារ និង សុខភាពបន្តពូជ

## (អង្គការរ៉ាឆា)

សំរាប់ការអនុវត្តន៍សកម្មភាព

គ្រប់គ្រង និងព្យាបាលជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

(រួមទាំងការធ្វើតេស្តរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ)

**២០០៩ ~ ២០១៣**

RACHA
Reproductive and Child Health Alliance

## សេចក្តីផ្តើម

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (រ៉ាឆា) បានឯកភាពគ្នាថា ការសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងការសំរបសំរួល រវាងស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល នឹងជួយពង្រឹងគុណភាព បង្កើនការប្រើប្រាស់សេវាថែទាំព្យាបាលការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ ការតេស្តឈាម និងការព្យាបាល ជំងឺស្វាយ ចំពោះស្ត្រីមានផ្ទៃពោះ ការប្រើប្រាស់ និងពង្រីកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ការលើកកំពស់សកម្មភាពបង្ការការចំលងមេរោគអេដស៍ កាមរោគ និងការផ្សព្វផ្សាយសេវាថែទាំសុខភាព ។

អង្គការ រ៉ាឆា ជាអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ នាខែកុម្ភៈ ឆ្នាំ ២០០៣ ។ អង្គការ រ៉ាឆា បានទទួលមូលនិធិពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្នុងការគាំទ្រការអនុវត្តន៍សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ការគ្រប់គ្រង និងថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ជំងឺស្វាយចំពោះស្ត្រីមានផ្ទៃពោះ និងសកម្មភាពបង្ការជំងឺអេដស៍ កាមរោគដទៃទៀត នៅក្នុងក្របខ័ណ្ឌការងារនៃផែនការយុទ្ធសាស្ត្រនៃកម្មវិធីបង្ការ និងថែទាំជំងឺអេដស៍ និងជំងឺកាមរោគរបស់ក្រសួងសុខាភិបាល ឆ្នាំ ២០០៦-២០១០ ។ អង្គការរ៉ាឆា នឹង ចូលរួមគាំទ្រ និងសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ មន្ទីរសុខាភិបាលខេត្ត/ស្រុកប្រតិបត្តិក្នុងដំណើរការសកម្មភាពបង្ការការចំលងមេរោគអេដស៍ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ នៅក្នុងខេត្ត/ក្រុងចំនួន ៥ គឺៈ ខេត្តសៀមរាប ពោធិសាត់ បន្ទាយមានជ័យ ព្រៃវែង និងកោះកុង នៅក្នុងកំឡុងឆ្នាំ ២០០៨-២០១៣ នេះ ។

នៅក្នុងកំឡុងឆ្នាំ ២០០៩-២០១៣ អង្គការ រ៉ាឆា នឹងបន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មន្ទីរសុខាភិបាលខេត្ត ដើម្បីពង្រឹងកម្មវិធីបង្ការ និងផ្សារភ្ជាប់រវាងកម្មវិធីបង្ការនឹងសេវាសុខភាពបន្តពូជ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ នៅតំបន់ ដែលអង្គការបានផ្តល់ការគាំទ្រ ។ អង្គការ រ៉ាឆា ធានាថារាល់សកម្មភាព និងថវិកាគាំទ្រ ដែលបានទទួលពីម្ចាស់ជំនួយ ( មូលនិធិប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិក សំរាប់ការអភិវឌ្ឍន៍អន្តរជាតិ USAID) នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិគ្រប់ជ្រុងជ្រោយ និងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ របស់ស្រុកប្រតិបត្តិ មន្ទីរសុខាភិបាលខេត្ត កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត ។

គោលបំណង សកម្មភាព និង ទីតាំងអនុវត្តការងារ សំរាប់កិច្ចសហប្រតិបត្តិការរួមគ្នាក្នុងកំឡុងឆ្នាំ ២០០៩-២០១៣មានរៀបរាប់ដូចខាងក្រោមនេះ :

## ១, គោលបំណង

- បង្កើនការប្រើប្រាស់សេវាគ្រប់គ្រងនិងថែទាំព្យាបាលជំងឺកាមរោគនៅតាមមណ្ឌលសុខភាព និងការស្រាវជ្រាវរក មេរោគស្វាយ ចំពោះស្ត្រីមេផ្ទះនិងដៃគូ និងក្រុមប្រឈមមុខ ផ្សេងទៀត នៅតាមសហគមន៍ ។
- ធ្វើអោយប្រសើរឡើងនូវសមត្ថភាពបុគ្គលិក ក្នុងការធ្វើរោគវិនិច្ឆ័យ និងថែទាំព្យាបាលជំងឺកាមរោគ ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគស្វាយ ប្រកបដោយគុណភាពខ្ពស់ ។
- បង្កើនចំណេះដឹងស្តីអំពីការបង្ការការចំលងមេរោគ/ជំងឺអេដស៍ ជំងឺកាមរោគ និងជំងឺរបេង-អេដស៍ ក្នុងចំណោមប្រជាជននៅតាមសហគមន៍ និងជួយធ្វើអោយពួកគាត់ប្រើប្រាស់ចំណេះដឹងទាំងនេះក្នុងការកាត់បន្ថយនូវការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់ តាមរយៈការអប់រំសុខភាពជូនប្រជាជនទូទៅ និងក្រុមប្រឈមមុខខ្ពស់នៅតាមសហគមន៍ (ក្រុមគ្រួសារដែលមានសមាជិករកស៊ីឆ្ងាយ) ។

## ២, ទីតាំង និងតំបន់សហការ

ក្នុងកិច្ចព្រមព្រៀងនេះ អង្គការ រ៉ាឆា ប្តេជ្ញានឹងពង្រីងសេវាគ្រប់គ្រង និង ថែទាំព្យាបាលជំងឺកាមរោគនៅ តាមមណ្ឌលសុខភាព ចំនួន៣ នៃស្រុកប្រតិបត្តិនិមួយៗក្នុងចំណោមស្រុកប្រតិបត្តិ (សរុប ចំនួន ៥១ មណ្ឌល) ដែលបានជ្រើសរើស ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងផ្តល់សេវាធ្វើតេស្តរកមេរោគស្វាយ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពចំនួន ៣៥ កន្លែង ដែលមានទីតាំងនៅក្នុងខេត្ត-ក្រុង ដែលមានសកម្មភាពស្រាប់ និងខេត្តដែលត្រូវពង្រីកថ្មី។ ការពង្រីកបន្ថែមសេវានឹងអាចធ្វើទៅបាន ដោយផ្អែកទៅលើការព្រមព្រៀងឯកភាពគ្នា រវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មន្ទីរសុខាភិបាលខេត្ត និងអង្គការរ៉ាឆា ។ ឈ្មោះខេត្ត ស្រុកប្រតិបត្តិ និងទីតាំងសេវាមានដូចខាងក្រោម នេះ :

**ក. ការគ្រប់គ្រង និងថែទាំជំងឺកាមរោគនៅតាមមណ្ឌលសុខភាព (៥១ មណ្ឌល)**

**ខេត្តសៀមរាប :**

- ស្រុកប្រតិបត្តិ សៀមរាប ក្រឡាញ់ និងអង្គរជុំ (កំពុងដំណើរការ ).
- ស្រុកប្រតិបត្តិ សូត្រនិគម ( នឹងដំណើរការ ).

**ខេត្តបន្ទាយមានជ័យ :**

- ស្រុកប្រតិបត្តិ អូជ្រៅ ព្រះនេត្រព្រះ ថ្មពួក និងមង្គលបុរី (កំពុងដំណើរការ)

**ខេត្តកោះកុង :**

- ស្រុកប្រតិបត្តិ ស្មាច់មានជ័យ និងស្រែអំបិល (នឹងដំណើរការ)

**ខេត្តព្រៃវែង :**

- គ្រប់ស្រុកប្រតិបត្តិ ទាំង ៧ (នឹងដំណើរការ)

**ខ. ការស្រាវជ្រាវរកមេរោគស្វាយលើស្ត្រីមានផ្ទៃពោះ (៣៥ កន្លែង)**

**ខេត្តសៀមរាប :**

- ស្រុកប្រតិបត្តិ សៀមរាប: ៤ មណ្ឌលសុខភាពកំពុងដំណើរការ (កន្ទ្រាំង បន្ទាយស្រី មណ្ឌលមួយ និង សៀមរាប)
- ស្រុកប្រតិបត្តិ អង្គរជុំ: ១ មណ្ឌលសុខភាពកំពុងដំណើរការ (ពួក)
- ស្រុកប្រតិបត្តិក្រឡាញ់: ១ មណ្ឌលសុខភាពកំពុងដំណើរការ (កំពង់ថ្កូវ) និងពង្រីក១មណ្ឌលសុខភាព
- ស្រុកប្រតិបត្តិ សូត្រនិគម : ២ មណ្ឌលសុខភាព នឹងដំណើរការ

**ខេត្តពោធិសាត់ :**

- ស្រុកប្រតិបត្តិ សំពៅមាស: ៤ មណ្ឌលសុខភាពកំពុងដំណើរការ (កណ្ដៀង ក្រគរ ក្រវ៉ាញ និង ពាល ញែក) នឹងពង្រីកបន្ថែម ១មណ្ឌលសុខភាព។
- ស្រុកប្រតិបត្តិបាកាន: ១ មណ្ឌលសុខភាពកំពុងដំណើរការ (បឹងខ្នារ) និងពង្រីកបន្ថែម ១មណ្ឌល សុខភាព។

**ខេត្តបន្ទាយមានជ័យ :**

- ស្រុកប្រតិបត្តិ អូជ្រៅ: ២ មណ្ឌលសុខភាពនឹងដំណើរការ
- ស្រុកប្រតិបត្តិ ព្រះនេត្រព្រះ ២ មណ្ឌលសុខភាពនឹងដំណើរការ
- ស្រុកប្រតិបត្តិ មង្គលបុរី ២ មណ្ឌលសុខភាពនឹងដំណើរការ
- ស្រុកប្រតិបត្តិ ថ្មពួក ១ មណ្ឌលសុខភាពនឹងដំណើរការ

**ខេត្តកោះកុង :**

- ស្រុកប្រតិបត្តិ ស្មាច់មានជ័យ: ២ មណ្ឌលសុខភាពនឹងដំណើរការ
- ស្រុកប្រតិបត្តិ ស្រែអំបិល: ២ មណ្ឌលសុខភាពនឹងដំណើរការ

**ខេត្តព្រៃវែង :**

- ស្រុកប្រតិបត្តិនាក់លឿង: ២ មណ្ឌលសុខភាពនឹងដំណើរការ
- ស្រុកប្រតិបត្តិ ៦ ទៀត: ១ មណ្ឌលសុខភាព ក្នុង១ស្រុកប្រតិបត្តិ នឹងដំណើរការ

## ៣, ការទទួលខុសត្រូវ

**ការទទួលខុសត្រូវរបស់អង្គការ វ៉ាឆា:**

អង្គការ វ៉ាឆា នឹង :

- គាំទ្រដល់វគ្គបណ្ដុះបណ្ដាល (វគ្គបណ្ដុះបណ្ដាលដំបូង និងវគ្គបំប៉ន) សំរាប់អ្នកផ្ដល់ប្រឹក្សា និងបុគ្គលិកមន្ទីរពិសោធន៏ សំរាប់ធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ និងគាំទ្រវគ្គបណ្ដុះបណ្ដាលបំប៉នដល់អ្នកផ្ដល់សេវាថែទាំព្យាបាលជំងឺកាមរោគ និងអ្នកអភិបាលសេវា នេះក្នុងតំបន់ដែល

បានផ្តល់ការគាំទ្រ។ ការគាំទ្ររួមមាន ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ ការស្នាក់នៅសំរាប់អ្នកចូលរួម និងគ្រូសំរបសំរួល/ជំនួយការ និងការផ្គត់ផ្គង់ផ្សេងៗ ទៀត ដែលជាតំរូវការ ។

- គាំទ្រដល់ការផ្គត់ផ្គង់សំភារៈនៅកន្លែងផ្តល់សេវាដូចជាៈ សំភារៈការិយាល័យ សំភារៈមន្ទីរពិសោធន៍ និងសំភារៈប្រើប្រាស់ផ្សេងៗទៀត ទៅតាមការចាំបាច់ សំរាប់អនុវត្តការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ ចំពោះស្ត្រី មានផ្ទៃពោះ។
- គាំទ្រការប្រជុំសំរបសំរួល ការពិនិត្យតាមដាន និងការអភិបាលការងារ ប្រចាំត្រីមាស និង-ឬប្រចាំ ឆមាស ពីស្រុក ប្រតិបត្តិការិយាល័យ ប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ផ្នែកគ្រប់គ្រងព្យាបាល ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជនៃមជ្ឈមណ្ឌលជាតិ និងផ្នែកមន្ទីរពិសោធន៍នៃវិទ្យាស្ថានជាតិស្រាវ ជ្រាវសុខភាពសាធារណៈ ។
- គាំទ្រ និងផ្គត់ផ្គង់ប្រតិករសំរាប់ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ នៅក្នុងរយៈពេលដែល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ ពុំទាន់មាន លទ្ធភាពផ្គត់ផ្គង់។
- ចូលរួមការប្រជុំ និងសិក្ខាសាលាអំពីការធ្វើផែនការជាមួយមជ្ឈមណ្ឌលជាតិ កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត ការិយាល័យស្រុកប្រតិបត្តិ។ ផែនការសកម្មភាពនឹងត្រូវ ដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិគ្រប់ជ្រុងជ្រោយប្រចាំឆ្នាំ។

## ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ នឹង :

- រៀបចំការបណ្តុះបណ្តាល (វគ្គបណ្តុះបណ្តាលដំបូង និងវគ្គបំប៉ន) ជូនដល់អ្នកផ្តល់ប្រឹក្សា និងដល់បុគ្គលិកផ្នែក មន្ទីរពិសោធន៍ ស្តីអំពីការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ រួមទាំងការគ្រប់គ្រង និង ផ្នែកផ្សេងទៀតដែលពាក់ព័ន្ធ។
- ចូលរួមក្នុងការបណ្តុះបណ្តាលបំប៉ន( ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញា)ដល់អ្នកផ្តល់សេវាថែទាំព្យាបាល ជំងឺកាមរោគ នៅតាមមណ្ឌលសុខភាព និងជំនាញនៃការអភិបាល ការគ្រប់គ្រង ថែទាំព្យាបាលជំងឺកាមរោគ ជូនដល់អ្នកអភិបាលនៅតាមស្រុកប្រតិបត្តិ។
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ជូនដល់បុគ្គលិក នៅកំពុងបំរើការនៅកន្លែងដែលមានសេវានេះ ។
- ផ្តល់ការណែនាំបង្ហាត់បង្ហាញដល់កន្លែងដែលទើបនឹងចាប់ផ្តើមដំណើរការសេវាធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ ។
- គ្រប់គ្រងការផ្គត់ផ្គង់សំភារៈបរិក្ខារ និងការចែកចាយ ការកត់ត្រា និងប្រព័ន្ធរបាយការណ៍ ។

- ពិនិត្យតាមដាន និងអភិបាលរាល់សកម្មភាពការងារដែលបានអនុវត្តនៅគ្រប់មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកដែលមាន សេវាថែទាំព្យាបាលជំងឺកាមរោគ និងការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ រៀងរាល់ត្រីមាសឬរៀងរាល់ឆមាស អាស្រ័យទៅតាមតំរូវការជាក់ស្តែង ។
- ផ្តល់ និងផ្គត់ផ្គង់ប្រតិករសំរាប់ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ នៅពេលណាដែលមជ្ឈមណ្ឌលជាតិមានលទ្ធភាពផ្គត់ផ្គង់បានសមស្រប។

## ៤. ប្រភពថវិកា និងការគាំទ្រ

ការគាំទ្រកិច្ចសហប្រតិបត្តិការ រវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ-មន្ទីរសុខាភិបាលខេត្ត និងអង្គការ ហ៊ាឆា ដើម្បីពង្រឹងគុណភាពសេវាផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ការគ្រប់គ្រង និងថែទាំព្យាបាលជំងឺកាមរោគ ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ និងបង្កើនចំណេះ ដឹងពីការបង្ការជំងឺអេដស៍-កាមរោគ ដល់ប្រជាជនទូទៅ ស្ត្រីមេផ្ទះ និងដៃគូរបស់គាត់ និងក្រុមប្រឈមមុខនៅសហគមន៍ ដែលនឹងអនុវត្តនៅតាមមណ្ឌលសុខភាព-មន្ទីរពេទ្យ និងសហគមន៍ ក្នុងស្រុក ប្រតិបត្តិចំនួន ១៩ ក្នុងបណ្តាខេត្ត ចំនួន ៥ និងក្រុងចំនួន ១ (ដូចរៀបរាប់ខាងលើ) ក្នុងចំនួនទឹកប្រាក់សរុប ១១៣.៣៩៥ ដុល្លារ :

- ឆ្នាំទី ១ ខែតុលា ២០០៨ ដល់ ខែកញ្ញា ២០០៩ : ១២.១៤៧ ដុល្លារ
- ឆ្នាំទី ២ ខែតុលា ២០០៩ ដល់ ខែកញ្ញា ២០១០ : ៣១.០៤៤ ដុល្លារ
- ឆ្នាំទី ៣ ខែតុលា ២០១០ ដល់ ខែកញ្ញា ២០១១ : ២៥.៧៥០ ដុល្លារ
- ឆ្នាំទី ៤ ខែតុលា ២០១១ ដល់ ខែកញ្ញា ២០១២ : ២៣.៧២៧ ដុល្លារ
- ឆ្នាំទី ៥ ខែតុលា ២០១២ ដល់ ខែកញ្ញា ២០១៣ : ២០.៧២៦ ដុល្លារ

## ៥. គោលការណ៍រួម

អង្គការ ហ៊ាឆា នឹងប្រើប្រាស់បទពិសោធន៍ដែលទទួលបានដើម្បីលើកគំរោងកម្មវិធីសំរាប់ ៥ ឆ្នាំ ពីខែតុលា ឆ្នាំ ២០០៨ ដល់ ខែកញ្ញា ឆ្នាំ ២០១៣។ សេចក្តីព្រាងនៃគំរោងកម្មវិធីទាំងនេះនឹងផ្ញើរជូន ទៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ នៅរាល់ចុងឆ្នាំនិមួយៗដើម្បីពិគ្រោះសុំយោបល់មុននឹងយកទៅអនុវត្ត ។ ការផ្លាស់ប្តូរ គំរោងកម្មវិធី នឹងត្រូវលើកយកទៅពិគ្រោះយោបល់ជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាម រោគ ។ អង្គការហ៊ាឆា ក៏ប្តេជ្ញាផងដែរថានឹងធ្វើការប៉ាន់ស្មានថវិការ លើសកម្មភាពបង្ការជំងឺអេដស៍ទៅមន្ទីរសុខាភិបាលខេត្ត-ការិយាល័យអេដស៍ខេត្ត ដើម្បីបញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។ អង្គការហ៊ាឆានឹងផ្តល់របាយការណ៍ សកម្មភាពការងារដែលបានអនុវត្តព្រមទាំងបទពិសោធន៍ដែលទទួលបាន ផ្ញើរជូនទៅមជ្ឈមណ្ឌល ជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៅរៀងរាល់ដំណាច់ឆមាសនិមួយៗ (ស្របទៅតាមអាណត្តិរបស់ គំរោង-ថវិកា) ។

ទំរង់ការទូទៅ ការសំរបសំរួល និងរាល់ការធ្វើផែនការសកម្មភាពទាំងអស់ខាងលើ នឹងត្រូវអនុវត្តរួមគ្នារវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ និងអង្គការរ៉ាឆា ដែលមានមន្រ្តីទំនាក់ទំនង គឺ ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ និងនាយិកាប្រតិបត្តិ ឬ នាយិការង នៃអង្គការ រ៉ាឆា ។

**វេជ្ជ. មាន ឈីវុន**

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង
ជំងឺអេដស៍ សើស្បែក និងកាមរោគ
កាលបរិច្ឆេទ : 15/07/2009

**ក. ចាន់ ធារី**

នាយិកាប្រតិបត្តិអង្គការ រ៉ាឆា

កាលបរិច្ឆេទ : 13/07/2009